World Vision

# កុមារ | សម្លេង | អំណាច

## របាយការណ៍រីកចម្រើនប្រចាំឆ្នាំ ២០១២

អង្គការទស្សនៈពិភពលោកកម្ពុជា



# មាតិកា


៦ សាររបស់នាយកប្រចាំប្រទេស
៧ សេចក្តីសង្ខេបពីកម្មវិធី
៨ ការបំផុសចលនាសហគមន៍
១០ សុខភាព អាហារូបត្ថម្ភ អេដស៍ និងអនាម័យទឹកស្អាត
១២ ការអប់រំ
១៤ ការការពារកុមារ
១៦ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងកសិកម្ម
១៨ ការតស៊ូមតិ
២០ ព័ន្ធកិច្ចគ្រិស្តបរិស័ទ
២២ កិច្ចការងារមនុស្សធម៌ និងជំនួយសង្គ្រោះបន្ទាន់
២៤ វីសិនហ្វាន់
២៦ របាយការណ៍ហិរញ្ញវត្ថុ

## ទស្សនវិស័យរបស់យើង
## គឺចង់ឃើញកុមារគ្រប់រូបមានជីវិតពេញបរិបូរណ៍

## សេចក្តីអធិស្ឋានរបស់យើង
## សូមឲ្យទឹកចិត្តមនុស្សគ្រប់រូបមានឆន្ទៈដើម្បីសម្រេចបំណងនេះ





# តើយើងជានរណា

អង្គការទស្សនៈពិភពលោក គឺជាអង្គការគ្រិស្តបរិស័ទជំនួយសង្គ្រោះបន្ទាន់ អភិវឌ្ឍន៍ និងតស៊ូមតិ ប្តេជ្ញាធ្វើការបម្រើកុមារ គ្រួសារ និងសហគមន៍ ដើម្បីជំនះលើភាពក្រីក្រ និងភាពអយុត្តិធម៌។



# តើយើងធ្វើអ្វីខ្លះ

តាមរយៈការជំរុញទឹកចិត្តដោយជំនឿរបស់គ្រិស្តបរិស័ទ អង្គការទស្សនៈពិភពលោកបម្រើប្រជាពលរដ្ឋគ្រប់រូប មិនប្រកាន់សាសនា ពូជសាសន៍ ជនជាតិ ឬភេទឡើយ។

# តម្លៃជាមូលដ្ឋាន



## យើងជាគ្រិស្តបរិស័ទ

យើងបានទទួលការត្រាស់ហៅឲ្យបម្រើអ្នកដទៃក្នុងភាពបរិបូរណ៍នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។



## យើងប្តេជ្ញាជួយដល់ជនក្រីក្រ

យើងបានត្រូវត្រាស់ហៅឲ្យសម្រាលតម្រូវការ និងទុក្ខវេទនា ភ្ជាប់ទំនាក់ទំនងរវាងអ្នកក្រ និងអ្នកមាន។



## យើងជាអ្នកឆ្លើយតប

យើងឆ្លើយតបចំពោះគ្រោះអាសន្នដែលគំរាមកំហែងដល់អាយុជីវិត ព្រមទាំងស្ថានភាពសេដ្ឋកិច្ចសង្គមស្មុគស្មាញដែលតម្រូវឲ្យមានការអភិវឌ្ឍយូរអង្វែង។



## យើងគោរពតម្លៃមនុស្ស

យើងចាត់ទុកមនុស្សទាំងអស់ថា ត្រូវបានបង្កើតនិងស្រឡាញ់ដោយព្រះជាម្ចាស់ ដោយម្នាក់ៗមានលក្ខណៈពិសេសទទួលសេចក្តីថ្លៃថ្នូរ ការគោរព និងមានតម្លៃក្នុងខ្លួន។



## យើងជាដៃគូ

ក្នុងនាមជាសមាជិកនៃអង្គការទស្សនៈ-ពិភពលោកអន្តរជាតិ យើងព្រមទទួលយកកាតព្វកិច្ចដែលមានការចូលរួមគោលដៅរួម និងមានគណនេយ្យភាពទៅវិញទៅមក។



## យើងជាអ្នកបម្រើដែលមានការទទួលខុសត្រូវខ្ពស់

យើងស្មោះត្រង់ចំពោះគោលបំណងនៃធនធានដែលយើងបានទទួល និងគ្រប់គ្រងធនធានទាំងនោះក្នុងរបៀបដែលនាំមកនូវផលប្រយោជន៍ជាអតិបរមាដល់ជនក្រីក្រ។





# សាររបស់នាយកប្រចាំប្រទេស

សូមគោរពមិត្តភ័ក្រ សហការី និងដៃគូជាទីគោរព

នេះជាកិត្តិយសរបស់ខ្ញុំបាទដែលបានណែនាំពីរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១២ ដែលបង្ហាញនូវ ការងារ និងស្នាដៃរបស់អង្គការទស្សនៈពិភពលោកកម្ពុជា។

យើងសូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយ អ្នកទំនុកបម្រុង និងសហការី ព្រមទាំងដៃគូរាជរដ្ឋាភិបាលរបស់យើងផងដែរចំពោះការបំពេញការងារដោយស្មោះត្រង់ ដើម្បីជីវិតប្រសើរឡើងសម្រាប់កុមារក្នុងប្រទេសកម្ពុជា។

តាមរយៈភាពជាដៃគូសំខាន់ៗ ការទំនាក់ទំនងដ៏រឹងមាំ និងការតស៊ូមតិថ្នាក់មូលដ្ឋាន យើងបានធ្វើការជាមួយសហគមន៍ជាពិសេស កុមារ និងយុវជនដើម្បីបន្លឺសម្លេងរបស់ពួកគេទៅដល់អ្នកធ្វើការសម្រេចចិត្តថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអ្នកផ្តត់ផ្គង់សេវា។ ដោយផ្តោតលើនិរន្តរភាពនៃការងារអភិវឌ្ឍន៍សហគមន៍ក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់របស់យើង យើងបានធ្វើការងារចូលរួមចំណែកជាវិជ្ជមានដល់ជីវិតកុមាររាប់ពាន់នាក់។ យើងធ្វើការងារគ្រប់ជ្រុងជ្រោយជាមួយសហគមន៍ ដើម្បីគាំទ្រលើគំនិតផ្តួចផ្តើមតាមផ្នែកជាច្រើនដូចជា  អប់រំ សុខភាព ការការពារកុមារ សេដ្ឋកិច្ច កិច្ចការងារឆ្លើយតប និងត្រៀមឆ្លើយតបនឹងគ្រោះមហន្តរាយ ប្រាក់កម្ចីខ្នាតតូច។

ស្របគ្នានិងប្រទេសកម្ពុជាមានព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំដូចជា ការបោះឆ្នោតឃុំ/សង្កាត់ បញ្ហាបណ្តេញចេញពីដីធ្លីដែលត្រូវបានលើកឡើងដោយប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ និងអង្គការសិទ្ធិមនុស្សនានា ការរៀបចំកិច្ចប្រជុំអាស៊ានប្រកបដោយជោគជ័យរបស់រាជរដ្ឋាភិបាល និងជាឆ្នាំមួយប្រកបដោយទុក្ខក្រៀមក្រំយ៉ាងក្រៃលែងចំពោះការយាងចូលវង្គត់របស់ព្រះវររាជបិតា ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ។

យើងទាំងអស់គ្នាមានការត្រេកអរដែលអង្គការទស្សនៈពិភពលោក និងក្រុមហ៊ុនវីសិនហ្វាន់ អាចបន្តពង្រីកទំហំការងាររបស់ខ្លួនទោះបីជាឆ្លងកាត់ឆ្នាំមួយដែលហិរញ្ញវត្ថុមិនទាន់ប្រសើរក៏ដោយ។ យើងមានអារម្មណ៍ថាទទួលព្រះពរដែលអាចពង្រីកឱកាសបម្រើជនងាយរងគ្រោះ រួមមានកុមារដែលជាអ្នកដ៏សំខាន់សម្រាប់ប្រជាជាតិកម្ពុជាដ៏អស្ចារ្យនេះ។

ទស្សនៈវិស័យសម្រាប់ឆ្នាំ២០១៣នេះ គឺបន្តជំហ៊ានការងារអភិវឌ្ឍន៍ដើម្បីភាពប្រសើរឡើងសម្រាប់ជីវិតកុមារដែលមានអ្នកទំនុកបម្រុង ម្ចាស់ជំនួយ និងដៃគូ នឹងបន្តការងារជាមួយពួកយើងដើម្បីសម្រេចគោលដៅនេះ។



ជេសិន អ៊ីវែន
នាយកប្រចាំប្រទេស
អង្គការទស្សនៈពិភពលោកកម្ពុជា

# សេចក្តីសង្ខេបពីកម្មវិធីរបស់អង្គការទស្សនៈពិភពលោកកម្ពុជា

នៅចុងឆ្នាំ២០១២ អង្គការទស្សនៈពិភពលោកកម្ពុជាបានប្រតិបត្តិកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន៤០នៅក្នុង៩ខេត្ត និងរាជធានីភ្នំពេញ ដែលបម្រើដល់កុមារទំនុកបម្រុងជាង៧៣,០០០នាក់ ព្រមទាំងគ្រួសារ និងសហគមន៍របស់ពួកគេផងដែរ។




កម្មវិធីអភិវឌ្ឍន៍តំបន់ដែលទទួលមូលនិធិតាមរយៈកម្មវិធីទំនុកបម្រុងកុមារ កំពុងតែអនុវត្តនៅក្នុងភូមិ និងសហគមន៍ដែលមានទីតាំងភូមិសាស្រ្តនៅផ្តុំគ្នាហើយនោះក៏ជាកន្លែងដែលអង្គការទស្សនៈពិភពលោកធ្វើការលើកស្ទួយជីវភាពរស់នៅរបស់កុមារ និងក្រុមគ្រួសាររបស់ពួកគេផងដែរ។ នៅឆ្នាំ២០១២ អង្គការទស្សនៈពិភពលោក បានបន្តការយកចិត្តទុកដាក់ជាក់លាក់មួយដែលមានបំណងប្រាថ្នាចង់ឃើញកុមារមានជីវិតប្រសើរឡើង គឺមានន័យថាកុមារគ្រប់រូបទទួលបានការអប់រំសម្រាប់ជីវិត មានសុខភាពល្អ ទទួលបាននូវបទពិសោធន៍នៃសេចក្តីស្រលាញ់ពីព្រះជាម្ចាស់ និងអ្នកជិតខាង ទទួលបាននូវការថែរក្សា និងការការពារ ហើយនិងការចូលរួមចំណែកក្នុងការសម្រេចចិត្តដែលមានផលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។

អង្គការទស្សនៈពិភពលោកក៏បានអនុវត្តគម្រោងនានាដែលមិនបានទទួលជំនួយតាមរយៈកម្មវិធីទំនុកបម្រុងផងដែរ គឺដើម្បីដោះស្រាយនូវបញ្ហាពិសេសៗដែលប៉ះពាល់ដល់កុមារ និងយុវជនងាយរងគ្រោះក្នុងប្រទេសកម្ពុជា មានដូចជាការជួញដូរមនុស្ស ការកេងប្រវ័ញ្ចលើកុមារ ពលកម្មកុមារ និងកុមាររស់នៅតាមផ្លូវ។

## គោលដៅជាយុទ្ធសាស្រ្ត ដើម្បីសម្រេចបាននូវ ជីវិតប្រសើរឡើងសម្រាប់កុមារ ២០១១-២០១៦

- បង្កើនចំនួនកុមារដែលមានការលូតលាស់មាំមួនល្អ
- បង្កើនចំនួនកុមារដែលទទួលបានការការពារពីការឆ្លងរោគនិងជំងឺផ្សេងៗ
- បង្កើនចំនួនកុមារដែលអាចអានអក្សរបាននៅអាយុ ១១ឆ្នាំ
- កុមារអភិវឌ្ឍបំនិនជីវិតផ្តល់ប្រយោជន៍ដល់ខ្លួនគេផ្ទាល់ និងទូទាំងសហគមន៍របស់គេដែរ
- កុមារទទួលបានការការពារពីការរំលោភបំពាន និងការកេងប្រវ័ញ្ចតាមរយៈការទប់ស្កាត់និងការការពារដ៏មានប្រសិទ្ធភាព ព្រមទាំងយន្តការស្តារឡើងវិញ
- កុមារទទួលបាននូវការថែបំប៉នទំនាក់ទំនងល្អជាមួយព្រះជាម្ចាស់ អ្នកជិតខាង និងអ្នកនៅជុំវិញខ្លួនរបស់ពួកគេ

ទិសដៅយុទ្ធសាស្រ្តរបស់អង្គការទស្សនៈពិភពលោក ពិតជាស្របទៅតាមយុទ្ធសាស្រ្តនានារបស់រាជរដ្ឋាភិបាល ជាពិសេសយុទ្ធសាស្រ្តវិស័យអប់រំ និងវិស័យសុខាភិបាល។ យើងប្តេជ្ញាធ្វើការរួមគ្នាជាមួយក្រសួងនានា ដូចជា ក្រសួងអប់រំ ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយពីថ្នាក់ជាតិរហូតដល់ថ្នាក់ភូមិ។

ដើម្បីសិក្សាបន្ថែមពីការងាររបស់អង្គការទស្សនៈពិភពលោកកម្ពុជា សូមចូលទៅទស្សនាគេហទំព័រ៖ **www.worldvision.org.kh**

# កុមារ សម្លេង អំណាច

**កម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន** ៤៤ + **ខេត្តចំនួន** ៩

នៅចុងឆ្នាំ២០១២ អង្គការទស្សនៈពិភពលោកកម្ពុជាមានកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន៤៤ ដែលកំពុងធ្វើ ប្រតិបត្តិការនៅក្នុងខេត្តចំនួន ៩។ ដើម្បីនិរន្តរភាព អង្គការទស្សនៈពិភពលោកបានផ្តល់អំណាច តាមរយៈការកសាងសមត្ថភាព ដល់សហគមន៍ ពិសេសកុមារ និងយុវជន ដើម្បីឲ្យពួកគេមានភាពជាម្ចាស់ការប្រសើរឡើងនាពេលអនាគត។ យុវជនក្លាយជាអ្នកដឹកនាំដ៏រឹងមាំក្នុងការផ្លាស់ប្រែសហគមន៍របស់ពួកគេ។



**ក្លិបយុវជន និងកុមារចំនួន** ៤៤០

ក្រុមក្លិបយុវជន និងកុមារចំនួន៤៤០ បានបង្កើតឡើង និងបានពង្រឹងសមត្ថភាពឲ្យចូលរួមយ៉ាងសកម្ម ក្នុងការងារអង្គការទស្សនៈពិភពលោកពាសពេញប្រទេស។ ពួកគេទទួលបានចំណេះដឹង ទំនាក់ទំនង ឲ្យមានការអភិវឌ្ឍន៍(C4D) ដែលអាចឲ្យពួកគេមានឥទ្ធិពលក្នុងកិច្ចការអភិវឌ្ឍន៍សហគមន៍របស់ពួកគេដ៏ប្រាកដមួយ។ ពួកគេលើកឡើងនូវគំនិតដែលទាក់ទងនឹងបញ្ហាសំខាន់ៗរបស់សហគមន៍របស់ពួកគេ ដល់អ្នកមានសក្តានុពលក្នុងការផ្លាស់ប្តូរ និងបង្កើនការចូលរួមរបស់ពួកគេតាមរយៈការបង្កើតធនធានដែលអាចចែករំលែកបាន ។ ក្នុងការផ្តល់អំណាចឲ្យយុវជន និងកុមារនិយាយតំណាងឲ្យសហគមន៍របស់ពួកគាត់ កម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន៣៧ បានទទួលវគ្គបណ្តុះបណ្តាល (C4D) និងកំពុងប្រើប្រាស់ឧបករណ៍អភិវឌ្ឍន៍នេះក្នុងវិធីសាស្រ្តដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជន និងកុមារ។



ក្នុងកិច្ចប្រឹងប្រែងពង្រឹងការងារត្រួតពិនិត្យកុមារទូទាំងប្រទេស ការផ្លាស់ប្តូរសំខាន់មួយក្នុងប្រតិបត្តិការកម្មវិធីកុមារទំនុកបម្រុងត្រូវបានដំណើរការឡើង។ តាមរយៈប្រព័ន្ធត្រួតពិនិត្យកុមារដ៏សាមញ្ញ និងបែបវិមជ្ឈការ សហគមន៍ឥឡូវនេះរឹតតែមានសមត្ថភាពប្រសើរឡើងក្នុងការកំនត់នូវភាពងាយរងគ្រោះដែលពាក់ព័ន្ធនឹងកូនៗរបស់ពួកគេ ដែលនេះអាចឲ្យឪពុកម្តាយ និងអ្នកអាណាព្យាបាលឆ្លើយតបនូវបញ្ហាផ្សេងៗទាន់ពេល និងមានប្រសិទ្ធភាព។

អង្គការទស្សនៈពិភពលោកមានជំនឿយ៉ាងមុតមាំ ក្នុងការបំផុសចលនាសហគមន៍ ដូច្នេះយើងនឹងបន្តបង្កើត និងលើកតម្កើងនូវភាពជាដៃគូជាមួយសហគមន៍ឲ្យបានរឹងមាំជាងមុន។

យុវជនតំណាងចំនួនបួនរូបបានចូលរួមវេទិកាថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិករបស់អង្គការទស្សនៈពិភពលោកក្នុងប្រទេសឥណ្ឌាដើម្បីចែករំលែកបទពិសោធន៍ និងរៀនពីប្រទេសផ្សេងៗផងដែរ។

ពោរពេញដោយទំនុកចិត្ត និងក្តីសង្ឃឹម យុវជនកម្ពុជាចំនួនប្រាំរូបមកពីជនបទ បានសរសេរសំបុត្រផ្ញើរជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា។ សំបុត្រទាំងនោះត្រូវបានផ្ញើរជូនសម្តេចតាមរយៈ នាយកអង្គការទស្សនៈពិភពលោកអន្តរជាតិ ក្នុងកិច្ចប្រឹងប្រែងស្វែងរកពន្លឺសម្រាប់ក្តីស្រមៃ និងការជម្រុញទឹកចិត្តកុមារកម្ពុជា ដែលតែងតែត្រូវបានគេមើលរំលង។

# ភ្នាក់ងារនៃការផ្លាស់ប្រែ



"ក្រោមកិច្ចគាំទ្រ និងសហប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល យើងបានបង្កើតជាបណ្តាញការពារកុមារ ដែលរួមមានក្រុមកុមារ យុវជនស្ម័គ្រចិត្ត ឪពុកម្តាយ ក៏ដូចជាអាជ្ញាធរគ្រប់លំដាប់ថ្នាក់។ ជានិច្ចកាល អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអង្គការមិនមែនរដ្ឋាភិបាលតែងតែបង្ហាញនូវកិច្ចគាំទ្រក្នុងការដោះស្រាយបញ្ហាដែលកើតមាននៅក្នុងសហគមន៍។ កត្តានេះ រឹតតែជំរុញរូបខ្ញុំផ្ទាល់ និងយុវជនដទៃទៀតចូលរួមក្នុងសកម្មភាពនានាក្នុងការបម្រើសហគមន៍ ដែលមានដូចជា ការអប់រំប្រជាជន ឪពុកម្តាយ យុវជន និងកុមារស្តីពីអំពើហិង្សាក្នុងគ្រួសារ សិទ្ធិមនុស្ស ក៏ដូចជាកិច្ចការពារកុមារ"។

ហ៊ុន នឿន អាយុ ២០ឆ្នាំ
ប្រធានក្រុមក្លឹបយុវជនពាមរាំង
ស្រុកលើកដែក ខេត្តកណ្តាល

## សំបុត្រផ្ញើរជូនសម្តេចនាយករដ្ឋមន្ត្រី

"ខ្ញុំសង្ឃឹមថាសម្តេចនឹងជួយអភិវឌ្ឍនៅទីកន្លែងផ្សេងៗទៀត ដែលពុំទាន់មានវត្តមានអង្គការក្រៅរដ្ឋាភិបាលដូចសហគមន៍របស់ខ្ញុំ។ សហគមន៍ និងគ្រួសាររបស់ខ្ញុំសង្ឃឹមថាប្រជាជនទាំងអស់នឹងគោរព ស្រឡាញ់ និងគាំទ្រសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សម្រាប់ការអភិវឌ្ឍន៍ប្រទេសជារៀងរហូតតទៅ"។

នី វណ្ណនេន អាយុ ១៥ឆ្នាំ
ប្រធានក្លិបកុមារ ភូមិព្រៃធំ
ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល



"ក្នុងនាមក្រុមយុវជនស្ម័គ្រចិត្តដែលកំពុងតែបំពេញការងារក្នុងសហគមន៍ នាងខ្ញុំសូមជម្រាបថា ពួកយើងខ្ញុំជានិច្ចកាល ទទួលបាននូវចំណេះដឹងជាច្រើនពីវគ្គបណ្តុះបណ្តាល ដែលរៀបចំឡើងដោយអង្គការទស្សនៈពិភពលោក។ ពួកយើងតែងតែមានឱកាសបង្ហាញសមត្ថភាពរបស់យើងតាមរយៈការសម្របសម្រួលក្លិបយុវជន និងកុមារ។ ពួកយើងខ្ញុំបានចូលរួមក្នុងកិច្ចប្រជុំ នៅក្នុងភូមិ និងសហគមន៍ ហើយពួកយើងខ្ញុំទទួលបានចំនេះដឹងយ៉ាងច្រើន ដែលអាចជួយពួកយើងខ្ញុំឲ្យជៀសផុតពីការរំលោភបំពានផ្សេងៗ។ ពួកយើងខ្ញុំ ក៏មានភាពប្រសើរឡើងផ្នែកចំណេះដឹងជាច្រើន ក្រោយពីបម្រើការងារក្នុងក្លិបកុមារ និងយុវជន ក៏ដូចជាធ្វើការជាមួយបុគ្គលិកអង្គការទស្សនៈពិភពលោក"។

ហុង ហ៊ុន អាយុ ១៨ឆ្នាំ
ប្រធានយុវជននៃឃុំព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្តាល



"ខ្ញុំសូមបង្ហាញនូវសេចក្តីអរគុណ ទៅដល់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុញ្ញាត្តិឲ្យអង្គការទស្សនៈពិភពលោក មានវត្តមាននៅក្នុងប្រទេសកម្ពុជា ដើម្បីអភិវឌ្ឍន៍សហគមន៍ដែលខ្ញុំកំពុងរស់នៅ។ កិច្ចគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ បានធ្វើឱ្យប្រជាសហគមន៍របស់ខ្ញុំមានភាពប្រសើរឡើងផ្នែកចំណេះដឹង"។

អេង សុខឃីន អាយុ ២០ឆ្នាំ
អ្នកប្រឹក្សាក្លិបកុមារ ភូមិអូល្មៀ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ



# រួមគ្នាថែទាំសុខភាពកុមារ



ដើម្បីធ្វើឲ្យសុខុមាលភាពកុមារមានភាពប្រសើរឡើងប្រកបដោយនិរន្តរភាព អង្គការទស្សនៈពិភពលោកបានផ្លាស់ប្តូរទៅរកការអនុវត្តន៍កម្មវិធីតាមរបៀបដែលប្រកបដោយភាពជាក់លាក់ និងដែលអាចជឿជាក់បាន ដើម្បីធានាថាកុមារមានអាហារូបត្ថម្ភល្អ និងបង្ការពីការបង្កពេគ និងជំងឺផ្សេងៗ។

ដើម្បីឆ្លើយតបទៅនឹងការកាត់បន្ថយបញ្ហាគ្រោះគ្រិនទៅលើកុមារ ការផ្តោតការយកចិត្តទុកដាក់ ក្នុងដំណាក់កាលសំខាន់ មានអត្ថប្រយោជន៍ គឺចាប់ពីពេលបដិសន្ធិនៅក្នុងផ្ទៃដល់ទារកមានអាយុ ២៤ខែ ឬ ហៅថា ១.០០០ថ្ងៃដំបូងសម្រាប់ជីវិត។ លើសពីនេះទៅទៀត អង្គការទស្សនៈពិភពលោកបន្តការផ្តល់ចំណេះដឹងអំពីការអនុវត្តន៍ដែលល្អក្នុងការចិញ្ចឹមទារក និង កុមារតូច ស្វែងរកការគាំទ្រមតិក្នុងការចែកចាយម្សៅវីតាមីនតាមរយៈប្រព័ន្ធសុខាភិបាល និង ការកសាងសមត្ថភាពបុគ្គលិក។

## គម្រោងសហគមន៍ដើម្បីថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះ

សមត្ថភាពក្នុងការគាំទ្រ និងថែទាំកុមារកំព្រា និងកុមារ ងាយរងគ្រោះ មានភាពរីកចម្រើនតាមរយៈផលប៉ះពាល់ជាវិជ្ជមាននៃក្រុមសន្សំប្រាក់ និងរបៀបបង្កើនចំណូលដល់គ្រួសារកុមារ។ ៦៥% នៃមេដឹកនាំក្រុមសន្សំប្រាក់ និង៩៣%នៃហិរញ្ញិកជាស្ត្រី។

## បង្ការការឆ្លង និងថែទាំម្តាយ និងទារកពីជំងឺអេដស៍



**៩៥%** នៃស្ត្រីមានផ្ទៃពោះ និងមាតាដែលមានកូនអាយុចន្លោះ ពី០ ទៅ ២៣ខែ បានទៅពិនិត្យផ្ទៃពោះយ៉ាងហោចណាស់ម្តងក្នុងកំឡុងពេលមានផ្ទៃពោះ



**៨០%** នៃស្ត្រីមានផ្ទៃពោះ និងមាតាដែលមានកូនអាយុចន្លោះ ពី០ ទៅ ២៣ខែ ទទួលបានការប្រឹក្សានិងលទ្ធផលធ្វើតេស្តឈាមរកមេរោគអេដស៍ ក្នុងកំឡុងពេលមានផ្ទៃពោះ



**៧៥.៨%** នៃស្ត្រីមានផ្ទៃពោះ បានសម្រាលកូនដោយមានជំនួយពីឆ្មបដែលមានវិជ្ជាជីវៈ

## អនាម័យនិងទឹកស្អាត

**ភូមិចំនួន ១៦៧** ស្ថិតក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន២៥បានអនុវត្តវិធីសាស្ត្រដឹកនាំអនាម័យដោយខ្លួនឯងទាំងស្រុង ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តអនាម័យក្នុងសហគមន៍

**សាលាបឋមសិក្សាចំនួន ៩៣** ក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន ១៨ ទទួលបានទឹកស្អាតសម្រាប់បរិភោគ និងប្រភពទឹកដែលមានភាពល្អប្រសើរ និងបង្គន់អនាម័យ

**បង្គន់អនាម័យចំនួន ១១.៣៦០** ត្រូវបានសាងសង់ដោយមិនមានជំនួយផ្នែកសម្ភារពីអង្គការទស្សនៈពិភពលោក

យោងតាមរបាយការណ៍ពី សហគមន៍ និងគ្រូបង្រៀន បង្ហាញថា កុមារ បានអនុវត្តទម្លាប់អនាម័យ ប្រសើរជាងមុន ដែលនេះធ្វើឲ្យពួកគេមានសុខភាពរឹងមាំទាំងក្នុងសហគមន៍ និងសាលារៀន



" ឥឡូវនេះ ខ្ញុំចេះស្រឡាញ់ និងថែទាំសុខភាពកូនៗ និងសុខភាពរបស់ខ្ញុំផ្ទាល់ "។

ជឹម ចាយ
៣៦

ចាយបានបន្ថែមថា " ខ្ញុំបានទទួលកញ្ចប់ថ្នាំវីតាមីនជាច្រើនសម្រាប់កូនរបស់ខ្ញុំ។ បើប្រៀបធៀបសុខភាពជាមួយនឹងកូនច្បងទាំងបី ខ្ញុំបានកត់សម្គាល់ឃើញថាកូនប្រុសទីបួនរបស់ខ្ញុំគឺមានសុខភាពប្រសើរ និងរឹងមាំជាងគេ។ វាពិតជារពឹស និងឆ្លាតទៀតផង។ខុសពីបងប្រុស និងបងស្រីរបស់វាដែលមិនចូលចិត្តបន្លែ វាពិតជាចូលចិត្តញ៉ាំបន្លែមែនទែន"។

# ការជំរុញ និងលើកទឹកចិត្ត ធ្វើឲ្យចាយចេះស្រឡាញ់ និងថែទាំសុខភាពកូនៗរបស់គាត់

ចាយបានសម្រាលកូនច្បងទាំងបីនាក់របស់នាងនៅផ្ទះ ដោយមានការជួយពីឆ្មបបុរាណម្នាក់ ដែលរៀនក្បួននេះពីចាស់ទុំរបស់គាត់។ ការសម្រាលកូនតាមទម្លាប់ដូនតា ដែលតម្រូវឲ្យគាត់ចំណាយត្រឹមតែអង្ករមួយចាន ចេកមួយស្និត និងប្រាក់កាសមួយចំនួនតូចប៉ុណ្ណោះ។

"កន្លងមក ខ្ញុំបានបង្រៀនកូនៗរបស់ខ្ញុំឱ្យញ៉ាំម្ហូបដូចមនុស្សធំទូទៅ ដូចជា បបរទឹកឆ្អិន ហើយជួនកាល ខ្ញុំក៏ផ្តល់បាយឱ្យពួកគេ ទោះបីជាពួកគេទើបតែមានអាយុប្រហែលជាបីខែក៏ដោយ។ ខ្ញុំមិនបានបំបៅដោះដល់ពួកគេញឹកញាប់ឡើយ ដោយហេតុថា ខ្ញុំមិនមានទឹកដោះបានគ្រប់គ្រាន់។ កូនៗរបស់ខ្ញុំតែងតែមានជំងឺរាករូស ហើយពួកគេមានសភាពស្គមស្គាំង និងស្លេកស្លាំងខ្លាំង"។







ចាយត្រូវបានអញ្ជើញឱ្យចូលរួមវគ្គបណ្តុះបណ្តាល ដែលរៀបចំដោយ អង្គការទស្សនៈពិភពលោក ស្តីអំពីវិធីសាស្រ្តដើម្បីធ្វើបបរមានសារជាតិគ្រប់មុខសម្រាប់កុមារតូចៗ ក៏ដូចជា វិធីថែទាំសុខភាពទារកមុន និងក្រោយពេលសម្រាល។

ចាយ បានប្រាប់ឱ្យដឹងថា " ក្នុងកំឡុងពេលមានផ្ទៃពោះកូនប្រុសទីបួន ខ្ញុំបានទៅកាន់មណ្ឌលសុខភាពជាទៀងទាត់ដើម្បីត្រួតពិនិត្យសុខភាព និងទទួលយកថ្នាំថែរក្សាគភ៌(វីតាមីនជំនួយមុនពេលសម្រាល )។ ខ្ញុំពិតជាស្រឡាញ់កូនរបស់ខ្ញុំ ហើយខ្ញុំប្តេជ្ញាចិត្តអនុវត្តរាល់អ្វីៗដែលខ្ញុំបានរៀនពីអង្គការទស្សនៈពិភពលោក"។

ចាយ បានបន្តថា " បុគ្គលិកអង្គការទស្សនៈពិភពលោក បានមកផ្ទះរបស់ខ្ញុំជារឿយៗ ដើម្បីផ្តល់ដំបូន្មានដល់ខ្ញុំឱ្យចេះថែរក្សាសុខភាព និងរស់នៅប្រកបដោយអនាម័យ ដើម្បីជៀសផុតពីជំងឺដង្កាត់ផ្សេងៗ។



# គុណភាពនៃជីវិត

អង្គការទស្សនៈពិភពលោកបាននឹងកំពុងធ្វើការជាដៃគូជាមួយស្ថាប័នពាក់ព័ន្ធពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន ដើម្បីពង្រឹងការអនុវត្តន៍កម្មវិធីសាលាកុមារមេត្រីរបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមចំណែកសម្រេចបានគុណភាពអប់រំដល់កុមារគ្រប់រូបនៅតាមតំបន់ការងារ។

**មត្តេយ្យសាលាចំនួន**
**២៩**
បានអនុវត្តគម្រោងអប់រំកុមារតូច និងបំណិនជីវិត ដោយមានការចូលរួមពីសហគមន៍

**ច្រើនជាង**
**១ ភាគ ៣**
នៃកម្មវិធីអភិវឌ្ឍន៍តំបន់ទាំងអស់ បានដាក់បញ្ចូលកម្មវិធីអប់រំកុមារតូច ដោយផ្តោតលើមត្តេយ្យសហគមន៍

**ស្ទើរតែ**
**១ ភាគ ២**
នៃកម្មវិធីអភិវឌ្ឍន៍តំបន់ទាំងអស់ បានដាក់បញ្ចូលនូវឧបករណ៍វាយតម្លៃសមត្ថភាពអំណានរបស់កុមារ

**កុមារ និងយុវជន ចំនួន**
**២០៣នាក់**
បានទទួលការបណ្តុះបណ្តាលអំពីការអប់រំបំណិន ជីវិតទាំងប្រាំ ( ការគិត ការគ្រប់គ្រងអារម្មណ៍ ទំនាក់ទំនង ការប្រាស្រ័យទាក់ទង និង ការទទួលខុសត្រូវក្នុងសង្គម )

ដោយសារតែកង្វះផ្នែកធនធាន សម្ភាររៀន និងបង្រៀន សមត្ថភាពបង្រៀនរបស់គ្រូ និងការចូលរួមពីអាណាព្យាបាល ជាហេតុធ្វើឲ្យសមត្ថភាពនៃការអាន ការសរសេរ គណនាលេខ និងបំណិនជីវិតជាមូលដ្ឋានរបស់សិស្សានុសិស្សនៅមានកម្រិតនៅឡើយ។



# តូច ប៉ុន្តែជាក្មេងស្រីដ៏អស្ចារ្យ



## វង្សា
## ១០

" ខ្ញុំចង់ឱ្យមិត្តរបស់ខ្ញុំ ក្លាយជាសិស្សពូកែដូចខ្ញុំ ហើយខ្ញុំតែងតែបើកឱកាសឱ្យពួកគេសាកសួរខ្ញុំនូវសំនួរទាំងឡាយទាក់ទងនឹងការសិក្សា។ ខ្ញុំចូលចិត្តធ្វើបែបនេះ ពីព្រោះខ្ញុំចូលចិត្តចែករំលែករាល់ចំណេះដឹងទាំងឡាយរបស់ខ្ញុំជាមួយអ្នកដទៃ "។

ក្រុមកុមារមួយក្រុម ដែលមានគ្នាប្រមាណ ៣០នាក់ អាយុពី ៤ទៅ១០ឆ្នាំ កំពុងអង្គុយក្នុងជួរដោយមានរបៀប នៅពីមុខថ្នាក់រៀនមួយក្នុងស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។ កុមារីតូចម្នាក់កំពុងឈរនៅខាងមុខជួរ និងដើរតួនាទីជាគ្រូបង្រៀន។ កុមារីម្នាក់នេះមាន ឈ្មោះ គៀន វង្សា អាយុ១០ឆ្នាំ ជាសិស្សថ្នាក់ទី៤ និងជាកុមារទំនុកបម្រុងនៃអង្គការទស្សនៈពិភពលោក។

វង្សា ជាសិស្សដែលជាប់ចំណាត់ថ្នាក់លេខមួយ និងជាកូនច្បង ក្នុងចំណោមបួននាក់ក្នុងគ្រួសារកសិករបានថ្លែងថា "ម្តាយ និងមិត្តភក្តិរបស់ខ្ញុំបានលើកទឹកចិត្តឱ្យខ្ញុំបង្រៀនអ្នកដទៃទៀត។ ខ្ញុំត្រូវជួយពួកគេឲ្យបានយល់អំពីមេរៀនផ្សេងៗ"។

រីន សុមាលី ជាគ្រូបង្រៀនរបស់វង្សាបានប្រាប់ឱ្យដឹងថា " វង្សាតែងតែជួយដល់សិស្សដទៃទៀត ឱ្យបានយល់អំពីមេរៀនផ្សេងៗ ហើយនាងមិនដែលរើសអើងចំពោះសិស្សដែលងាយរងគ្រោះទាំងអស់នោះទេ"។

សោភា ម្តាយរបស់វង្សាបាននិយាយថា "ដំបូងឡើយ កូនស្រីរបស់គាត់ គ្រាន់តែបង្រៀនប្អូនរបស់នាងប៉ុណ្ណោះ។ ក្រោយមកក្មេងៗចេះតែបន្តឱ្យវង្សាបង្រៀនច្រើនឡើងៗ ក្រោយពីពួកគេឃើញការបង្រៀនរបស់នាង។ វង្សា មានទឹកចិត្តមោះមុតក្នុងការជួយអ្នកដទៃ។ ជួនកាល នាងជិះកង់របស់នាងទៅកាន់ផ្ទះកុមារដទៃ ហើយបានបង្រៀនកុមារទាំងនោះឱ្យរៀនអាននិងសរសេរ។ កុមារដែលមិនចេះអាន និងសរសេរ មានការផ្លាស់ប្តូរដោយពួកគេចេះទាំងអាន ទាំងសរសេរ។

វង្សាបានប្រាប់ឱ្យដឹងថា "សកម្មភាពនៅក្នុងក្លិបរបស់ខ្ញុំ មានលក្ខណៈស្រដៀងនឹងអ្វីដែលយើងធ្វើក្នុងថ្នាក់។ កុមារនាំគ្នាឈរជាជួរ ហើយខ្លួនខ្ញុំផ្ទាល់ជាអ្នកដឹកនាំច្រៀងចំរៀង និងរំលឹកមេរៀនគណិតវិទ្យា។ បន្ទាប់មក ខ្ញុំបង្រៀនអំពីពាក្យពិបាកៗ និងពន្យល់ឱ្យពួកគេយល់"។

វង្សា បានលើកសំណើសុំការគាំទ្រក្នុងការសាងសង់ថ្នាក់រៀនដើម្បីរៀបចំវគ្គសិក្សាក្រៅម៉ោង ជាលទ្ធផល សហាគមន៍ផ្តល់ជាសម្ភារសាងសង់ ហើយឪពុកម្តាយ វង្សា យល់ព្រមផ្តល់ទីធ្លាសម្រាប់សាងសង់ថ្នាក់រៀន អង្គការទស្សនៈពិភពលោក ក៏បានគាំទ្រទៅលើសំណើរបស់វង្សាផងដែរ។

វង្សា ស្រម័យចង់ក្លាយជាគ្រូបង្រៀន។









# ការពារកុមារចាប់ផ្តើមនៅផ្ទះ

ការពារកុមារនៅផ្ទះ និងក្នុងសហគមន៍របស់ពួកគេ ផ្តល់លទ្ធភាពឲ្យពួកគេដើម្បីថ្លែងនូវក្តីកង្វល់របស់ពួកគេទៅកាន់អ្នកធ្វើការសម្រេចចិត្ត។ នេះជាគោលដៅរបស់អង្គការទស្សនៈពិភពលោក។ ដើម្បីទទួលបានគោលដៅនេះ កម្មវិធីការពារកុមារបានពង្រីកគម្រោងរៀបចំសហគមន៍ដើម្បីការពារកុមារ ពីកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន៤ ដល់១៤ ក្នុងឆ្នាំ២០១២។

គម្រោងរៀបចំសហគមន៍ដើម្បីការពារកុមារ បានផ្តល់អំណាចដល់យុវជន គណៈកម្មការការពារកុមារ និងបណ្តាញផ្សេងៗទៀត អាចឲ្យពួកគេរាយការណ៍យ៉ាងសកម្មនូវករណីគ្រោះថ្នាក់របស់កុមារដល់អាជ្ញាធរ ប៉ូលីស និងអង្គការក្រៅរដ្ឋាភិបាល។



យុវជនចំនួន
**១.៣៨៩នាក់**
ជាសមាជិក នៃក្លិប
យុវជនចំនួន៥៨



ប្រជាជនចំនួន
**៤២៤នាក់**
ជាសមាជិក នៃបណ្តាញ
ការពារកុមារចំនួន៧



ប្រជាជនចំនួន
**៩០៦នាក់**
ជាសមាជិក នៃគណៈកម្មការ
ការពារកុមារចំនួន៤៨

---

គម្រោងស្តារនីតិសម្បទាកុមារីរងគ្រោះរបស់អង្គការទស្សនៈពិភពលោក ត្រូវបានជឿទុកចិត្តលើការផ្តល់គុណភាពថែទាំ និងគុណភាពការពារផ្នែកច្បាប់ដល់កុមារីរងគ្រោះពីការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ។ ក្នុងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ អង្គការទស្សនៈពិភពលោកបាន សហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងយុត្តិធម៌។



កុមារីចំនួន
**២៦នាក់**
និងគ្រួសាររបស់ពួកគេបាន
ឈ្នះក្តីប្រឆាំងនឹងជនល្មើស



កុមារីចំនួន
**៨០នាក់** និងគ្រួសារ បានទទួលវគ្គបណ្តុះបណ្តាល
សវនាការតុលាការប្រឌិត ដើម្បីជួយពួកគេឲ្យយល់ពីនីតិវិធីតុលាការ និងដំណើរការកាត់ក្តី

---

គម្រោងកូនប្រុសខ្ញុំបានធ្វើការការពារការរំលោភបំពានផ្លូវភេទលើកុមារា ក្នុងទីក្រុងភ្នំពេញ និងខេត្តបាត់ដំបង។ អង្គការទស្សនៈពិភពលោកបានលើកកម្ពស់ការយល់ដឹងនូវបញ្ហាសំខាន់ៗពីវិធី ស៊ើបអង្កេត និង កិច្ចការពារ ក៏ដូចជាបញ្ជូនកុមាររងគ្រោះទៅមណ្ឌលថែរក្សានិងផ្តល់នូវសេវាផ្លូវច្បាប់ តាមរយៈការធ្វើការជាដៃគូជាមួយ អាជ្ញាធរក្នុងតំបន់ ប៉ូលីស សហគមន៍កុមារ ក្រុមជំនុំ វត្តអារាម អ្នកសារព័ត៌មាននិងអង្គការដៃគូមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ។



ក្រុមជំនុំចំនួន
**១២** ក្នុងខេត្តបាត់ដំបង
បានធ្វើការផ្សព្វផ្សាយ
ចំណេះដឹងស្តីពីការរំលោភផ្លូវភេទ
កុមារាតាមសហគមន៍របស់ពួកគាត់



វត្តអារាមចំនួន
**១២** បានធ្វើការផ្សព្វផ្សាយ
ព័ត៌មាន និងពង្រឹង
យន្តការដើម្បីការពារកុមារា
ដែលរស់នៅក្នុងវត្តអារាម

អង្គការទស្សនៈពិភពលោកក៏បន្តធ្វើការជាមួយកុមារធ្វើការ និងរស់នៅតាមផ្លូវក្នុងរាជធានីភ្នំពេញ។ កុមារចំនួន៣២នាក់កំពុងទទួលបានទីជម្រក អាហារ និងការអប់រំក្រៅប្រព័ន្ធ នៅមជ្ឈមណ្ឌលទំពាំងស្នងឫស្សី។

ក្រុមការងារបានធ្វើការងារផ្តល់ចំណេះដឹងដល់កុមារចំនួនជាង ៣០០នាក់ ស្តីពីសិទ្ធិកុមារ ជំងឺអេដស៍ និងមេរោគអេដស៍ ការសេពគ្រឿងញៀន អនាម័យ និងការជួញដូរកុមារ។



# សង្គ្រោះសារឿន

"ប្រសិនបើយើងមិនអន្តរាគមន៍ទាន់ពេលទេ នោះយើងនឹងបាត់បង់នាង"។

មេឃុំ រឿន ជ្រឹន
៥៦

ជា សារឿនបោះបង់ការសិក្សាទៅធ្វើការងារនៅរោងចក្រកាត់ដេរតាំងពីនាងមានអាយុ១២ឆ្នាំមកម្ល៉េះ។ ស្ត្រីវ័យក្មេងម្នាក់ដែលគេស្គាល់ថាជាមេខ្យល់ធ្វើការនៅក្នុងរោងចក្របានល្បួងសារឿនដែលជាអ្នកមានការគិតក្មេងវ័យនៅឡើយ ឲ្យទៅធ្វើការជាអ្នកថែទាំផ្ទះក្នុងប្រទេសម៉ាឡេស៊ីជាមួយនឹងប្រាក់ខែខ្ពស់។

មេខ្យល់ជាអ្នកដែលបានលួងលោមក្មេងស្រីក្មេងៗដោយសន្យាផ្តល់ការងារធ្វើ ក៏ប៉ុន្តែបន្ទាប់មកលក់កុមារីទៅក្នុងអាជីវកម្មផ្លូវភេទ ឬកម្លាំងពលកម្មកុមារ។

ព្រោះតែអង្គការទស្សនៈពិភពលោកបានធ្វើការងារនៅមូលដ្ឋានរួចជាស្រេចបងស្រីរបស់សារឿនធ្វើការប្រកាសអាសន្នអំពីការបាត់ខ្លួនរបស់ប្អូនស្រី។ ម្តាយរបស់សារឿនទៅរកមេឃុំជ្រឹនភ្លាម។ មេឃុំជ្រឹនដឹងហើយបានភ្ជាប់ទំនាក់ទំនងទៅមន្ត្រីផ្សេងទៀតដូចជា លោក ឃី សារីម ដែលមានទំនាក់ទំនងនឹងប៉ូលីស។ ឪពុកមារបស់នាងបានចូលរួមវគ្គសិក្ខាសាលាដែលរៀបចំដោយអង្គការទស្សនៈពិភពលោកស្តីពីការរំលោភ និងការជួញដូរកុមារ។ គាត់បានដឹងថាសារឿនកំពុងស្ថិតក្នុងការគំរាមកំហែងពីការជួញដូរ។ គាត់ក៏ប្រញាប់ប្រញាល់ទៅរោងចក្រ ដើម្បីស្វែងរកស្វាមីរបស់ស្ត្រីមេខ្យល់។ ប៉ូលីសដែលបានបណ្តុះបណ្តាលបានមកជួយក្នុងការសាកសួរអង្កេតបន្ថែម។ ទីបញ្ចប់សារឿនត្រូវបានជួយសង្គ្រោះ។

ថ្នាក់ដឹកនាំយុវជនមកពីក្លិបយុវជនរបស់អង្គការទស្សនៈពិភពលោកបានមកសួរសុខទុក្ខសារឿន និងពួកគេបាននៅកំដរនៅផ្ទះរបស់សារឿនកំឡុងពេលសារឿនបាត់ខ្លួនលើកទឹកចិត្តដល់ក្រុមគ្រួសាររបស់សារឿន។ ប៉ូលីសបានឃាមការពារក្រុមគ្រួសារសារឿនដោយដឹង ថាមេខ្យល់បានរត់គេចពីសំណាញ់ច្បាប់ក្នុងទីក្រុងភ្នំពេញហើយអាចបន្តការ



ភិតភ័យដល់គ្រួសាររបស់សារឿនទៀត។

រហូតដល់ពេលនេះយុវជន និងកុមារ ចំនួន ៦០០នាក់បានឆ្លងកាត់កម្មវិធីវិថីសន្តិភាពរបស់អង្គការទស្សនៈពិភពលោក។ វិថីសន្តិភាពបានបង្រៀនថា កុមារមានតម្លៃ និងគួរត្រូវបានការពារ ហើយការវាយធ្វើបាប និងការកេងប្រវ័ញ្ចគឺជាកំហុស រីឯការអប់រំគឺសំខាន់បំផុត។









# ចំណូលប្រសើរ ធ្វើឲ្យ ជីវិតកុមារប្រសើរឡើង

គ្រួសារក្រីក្របំផុតនៅកម្ពុជាភាគច្រើននៅតែពឹងផ្អែកលើរបរកសិកម្ម សម្រាប់ជីវភាពរស់នៅរបស់ពួកគេ។ ពួកគេនៅតែគ្មានជំនាញ ហើយប្រកបរបរចិញ្ចឹមជីវិតតាមរយៈការងារមិនទៀងទាត់ និងមិនពិតប្រាកដ ដែលទាំងនេះបង្ខំពួកគេធ្លាក់ចូលក្នុងការធ្វើចំណាកស្រុក បណ្តាលឲ្យកើនឡើងនូវភាពងាយរងគ្រោះចំពោះកុមារ។

កិច្ចអន្តរាគមន៍របស់អង្គការទស្សនៈពិភពលោកបានផ្តោតលើរបៀបដែលអាចមានផលវិជ្ជមានដល់កុមារ។ បើទោះបីជាចំណូលទាំងនោះមិនបានបង្ហាញឲ្យឃើញជារូបរាងយ៉ាងណាក្តី ប៉ុន្តែន័យមួយគឺដើម្បីជីវិតប្រសើរឡើងសម្រាបកុមារ។ គម្រោងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងកសិកម្មត្រូវបានយកចិត្តទុកដាក់លើវិធីសាស្ត្របីដូចខាងក្រោម៖

**លើកស្ទួយការសន្សំប្រាក់** បង្កើតទម្លាប់សន្សំសំចៃក្នុងចំណោមគ្រួសារក្រីក្រ និងអភិវឌ្ឍជំនាញដើម្បីមីក្រូហិរញ្ញវត្ថុ។

**ប្រជាជនចំនួន** ២៣.៥២១នាក់ → ចូលជាសមាជិក → **ក្រុមសន្សំប្រាក់ចំនួន** ១.២៣៦ក្រុម

**ការសម្របសម្រួលលើអាជីវកម្ម** ឱកាសសេដ្ឋកិច្ចក្នុងស្រុកសម្រាប់គ្រួសារ និងសហគមន៍ និងអភិឌ្ឍន៍កសិកម្មតាមតំបន់ចំពោះការដាំដំណាំ និងចិញ្ចឹមសត្វ ដែលអាចឲ្យកិសករចែកចាយព័ត៌មានរួមគ្នា ចរចារតម្លៃ ហើយនិងអភិវឌ្ឍជំនាញរបស់ពួកគេ។ ការបង្រៀនសហគមន៍ឲ្យចេះវិភាគអាជីវកម្ម ដាក់គោលដៅ ធ្វើផែនការ និងសម្របសម្រួលឲ្យចេះរកនូវអានុភាពដែលគាត់ត្រូវការ។

**សមាគមអភិវឌ្ឍន៍សិកម្មចំនួន** ៣១ បានទទួលការចុះឈ្មោះជាផ្លូវការ

**ភ្ជាប់ទៅនឹងសង្វាក់តម្លៃ** ផ្សារភ្ជាប់អ្នកផលិតជាមួយស្ថាប័នសាធារណៈ និងឯកជន ហើយនិងពាណិជ្ជកវដែលបានធ្វើដំណើរទៅកាន់ទីផ្សារកាន់តែធំទូលាយសម្រាប់ផលិតផលសហគមន៍។

**កម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន ១៧ បានបង្កើតមុខរបរអត្ថិភាពក្នុងតំបន់**

**៣០%** នៃសមាជិកសមាគមអភិវឌ្ឍន៍កសិកម្មជាគ្រួសារក្រីក្រ

**៨៧%** នៃអ្នកសន្សំប្រាក់ជាស្ត្រី

**៣២%** នៃអ្នកសន្សំប្រាក់ ធ្លាប់ជាគ្រួសារក្រីក្រ ហើយកុមារក្នុងគ្រួសារទាំងនេះទទួលបានផលប្រយោជន៍ច្រើនជាងគេ ដោយសារឪពុកម្តាយគេមានលទ្ធភាពប្រើប្រាស់សេវាសុខាភិបាល និងអប់រំនាពេលឥលូវនេះ

**អ្នកសន្សំប្រាក់ចំនួន ៤២នាក់** ជាជនពិការ





" អ្នកភូមិផ្សេង ៗទៀតទទួលបានការកើនឡើងទ្វេរដង ផ្នែកផលិតផលកសិកម្មរបស់ពួកគេ បើប្រៀបធៀបទៅនឹងឆ្នាំ២០១០។ ជីវិភាពរបស់ពួកយើងបានប្រសើរឡើងជាងពេលមុន។ អ្នកភូមិមានលទ្ធភាពបញ្ជូនកូន ៗពួកគេទៅសាលា "។

នី មុំ

៣៥

# ជីវិតប្រសើរឡើងសម្រាប់កូន។

នៅតាមបណ្តោយទន្លេមេគ្គ ភាគខាងត្បូងប្រទេសកម្ពុជា កសិករមកពីស្រុកលើកដែក កំពុងមមាញឹកប្រមូលភោគផលដំណាំរបស់ពួកគេ។



គេសង្កេតឃើញផ្ទះនីមួយៗ ពោរពេញទៅដោយគំនរពោត ហាក់ដូចជាកំរាលពណ៌មាស ត្រូវបានគេហាល នៅទីធ្លាក្នុងផ្ទះ និងនៅតាមដងផ្លូវ។ ចុងខែមិនា គឺជារដូវប្រមូលផល។

កសិករម្នាក់ ឈ្មោះនី មុំ មានអាយុ៣៥ឆ្នាំ មានអារម្មណ៍រីករាយឥតឧិបមាជាមួយនឹងទិន្នផលឆ្នាំនេះ ដោយសារផលិតផលពោត និងស្រូវ របស់គ្រួសារគាត់កើនឡើងទ្វេដងបើប្រៀបធៀបទៅនឹងឆ្នាំ២០១០។ ពួកគេទទួលផលពី៤ទៅ៨តោនក្នុងមួយហិកតា។ គាត់តែងតែចង់ឃើញកូនប្រុសទាំងបួននាក់របស់គាត់ ដែលសុទ្ធតែជាកុមារទំនុកបម្រុង មានអនាគតប្រសើរឡើង។ មុំបានបន្តថា"ខ្ញុំមិនចង់ឃើញកូនៗរបស់ខ្ញុំក្លាយជាមនុស្សអវិជ្ជាដូចរូបខ្ញុំនោះទេ"។



ដោយសារធនធានទឹកនៅខ្វះខាត គ្រួសាររបស់មុំ មិនអាចដាំដំនាំពោតបានទេ នារដូវប្រាំង។ នេះជាកត្តាដែលបង្កឱ្យទិន្នផលពោតមានការធ្លាក់ចុះ ផ្តល់ប្រាក់ចំណូលទាប និងបង្ខំចិត្តឱ្យកូនៗគាត់គេចពីសាលា ឬបោះបង់ការសិក្សា ដើម្បីរកប្រាក់ចំណូលបន្ថែមសម្រាប់ផ្គត់ផ្គង់គ្រួសាររបស់ពួកគេ។

នៅខែឧសភា ឆ្នាំ២០១០ អង្គការទស្សនៈពិភពលោកបានស្តារប្រព័ន្ធធារាសាស្ត្រប្រវែង ២.៥០៧ មែត្រ ដែលផ្តល់ប្រយោជន៍ដល់ប្រជាជនជាង១២០គ្រួសារក្នុងភូមិ។



ឆ្នាំនេះ មុំ និងប្តីរបស់គាត់បង្កបង្កើនផលលើដីកម្មសិទ្ធពួកគេមួយហិកតា និងជួលដីបន្ថែមចំនួន មួយហិកតាកន្លះទៀត ដើម្បីដាំដំណាំស្រូវ និងពោត។ មុំនិយាយដោយទឹកមុខញញឹមថា " ពួកយើងហ៊ានបង្កើនការដាំដុះលើដីបន្ថែមទៀត ដោយហេតុថា មានធនធានទឹកគ្រប់គ្រាន់ ទោះបីជារដូវប្រាំងយ៉ាងណាក្តី។ យើងបានទទួលប្រាក់ចំណូលយ៉ាងច្រើនពីការបង្កបង្កើនផលនេះ"។

មុំនិយាយថា"ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការទស្សនៈពិភពលោក ដែលបានជួយដល់ភូមិរបស់ខ្ញុំតាមរយៈការស្តារប្រលាយទឹក ការសង់អណ្តូងទឹក ផ្តួចផ្តើមឱ្យពួកយើងសង់បង្គន់អនាម័យនៅតាមផ្ទះ ផ្តល់ធុងចម្រោះទឹក និងតំឡើងអណ្តូងស្នប់នៅតាមដីស្រែចំការរបស់ពួកយើង"។



# សម្លេង និងសកម្មភាពប្រជាជន

ក្នុងឆ្នាំ២០១២ បុគ្គលិកអង្គការទស្សនៈពិភពលោកចំនួន១៧៨នាក់ គ្រូបង្រៀនចំនួន៧២រូប គណៈកម្មការគាំទ្រគ្រូបង្រៀន អាជ្ញាធរមូលដ្ឋាន ប្រធានក្លិបយុវជន និងក្លិបកុមារ ព្រមទាំងសមាជិកនៃអង្គការក្នុងសហគមន៍បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី សម្លេង និង សកម្មភាពប្រជាជន ដែលជាមធ្យោបាយតស៊ូមតិថ្នាក់មូលដ្ឋាន។

ក្នុងការប្រើចំណេះដឹងជាមូលដ្ឋានសម្រាប់ការតស៊ូមតិ បុគ្គលិកអង្គការទស្សនៈពិភពលោកបានសម្របសម្រួលកិច្ចពិភាក្សារវាងសមាជិកសហគមន៍(អ្នកទទួលបានសេវា) និងអាជ្ញាធរ(អ្នកផ្តល់សេវា ឬ សម្រេចចិត្ត) ដើម្បីអភិវឌ្ឍន៍ និងពង្រឹងទំនាក់ទំនងរបស់ពួកគេ។កិច្ចការនេះផ្តល់ភាពប្រសើរឡើង ទាក់ទងនឹងការផ្តល់សេវាសាធារណៈ និង គណនេយ្យភាពផ្នែករដ្ឋបាល និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងពលកម្មកុមារ អង្គការទស្សនៈពិភពលោកបានធ្វើការដោយផ្ទាល់ជាមួយរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលដទៃទៀត ក្នុងការបង្កើតនូវគោលការណ៍ថ្មីៗស្តីពីកុមារ ការធ្វើឱ្យប្រសើរឡើងផ្នែកច្បាប់ និងលុបបំបាត់ចន្លោះប្រហោងក្នុងច្បាប់។ កិច្ចព្រមព្រៀងឆ្លងកាត់ព្រំដែន ដែលត្រូវបានស្គាល់ថា ច្បាប់ការពារអនិតិជន រវាងកម្ពុជា និងថៃស្ថិតក្នុងដំណើរការយល់ព្រមជាផ្លូវការ។

នៅឆ្នាំ ២០១២ ក្រោមកិច្ចពុះពារ ក្នុងការកាត់បន្ថយអត្រាមរណមាតា និងទារក អង្គការទស្សនៈពិភពលោកបានដាក់ចេញនូវការងារគ្រឹះសម្រាប់យុទ្ធនាការក្នុងពេលឆាប់ៗខាងមុខនេះ ដោយផ្តោតលើការបំផុសចលនា និងជំរុញរាជរដ្ឋាភិបាលកម្ពុជា ផ្លាស់ប្តូរ ធ្វើឱ្យប្រសើរ និងអនុវត្តគោលការណ៍ដែលទាក់ទងនៅនឹងសុខភាព និង អាហារូបត្ថម្ភរបស់មាតានិងទារក។



# ក្ដីសុបិន្ដប្រកបដោយភាពវៃឆ្លាត



" ខ្ញុំរីករាយក្នុងការធ្វើកិច្ចការបំរើសហគមន៍របស់ខ្ញុំ។ ខ្ញុំនឹងបន្ដចូលរួមរាល់សកម្មភាពក្នុងសហគមន៍ ព្រោះខ្ញុំចង់យល់ដឹងរឿងគ្រប់យ៉ាងពាក់ព័ន្ធនឹង ប្រជាសហគមន៍របស់ខ្ញុំ ហើយខ្ញុំនឹងបន្ដរួមចំណែកដោះស្រាយបញ្ហាក្នុងសហគមន៍របស់ខ្ញុំ"។

សិរីវឌ្ឍ
១៥



" អ្វីដែលខ្ញុំចង់ឃើញ គឺកុមារទាំងអស់បានទៅសាលារៀន ហើយពួកគេម្នាក់ៗមានចំណេះដឹង។ នៅពេលនោះ អ្នកភូមិរបស់ខ្ញុំនឹងមានភាពរុងរឿង និងសំបូរអ្នកមានចំណេះដឹង"

នេះជាការប្ដេជ្ញាចិត្ដរបស់សឿត សិរីវឌ្ឍ អាយុ១៥ឆ្នាំ ជាប្រធានក្រុមប្រឹក្សាសិស្ស នៃអនុវិទ្យាល័យហាប់ ស្រុកគាស់ក្រឡ ខេត្ដបាត់ដំបង។ ស្រុកនេះជាស្រុកដែលមានអត្រាខ្ពស់ នៃជនចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ និងម៉ាឡេស៊ី។ ក្មេងៗតែងតែផ្លាស់ប្ដូរទីលំនៅជាមួយឪពុកម្ដាយដែលទៅធ្វើការនៅទីនោះ។ នេះជាមូលហេតុដែលធ្វើឱ្យពួកគេមិនអាចទៅសាលារៀនបាន។

" ក្រុមការងាររបស់ខ្ញុំធ្វើការរួមគ្នាដើម្បីលើកកម្ពស់ការយល់ដឹងទៅដល់ឪពុកម្ដាយ ដើម្បីឱ្យពួកគេបញ្ជូនកូនទៅសាលារៀន។ កាលពីដើមចាស់ៗនៅក្នុងសហគមន៍របស់យើង មិនសូវសប្បាយចិត្ដនឹងសកម្មភាពយើងឡើយ។ ប៉ុន្ដែក្រោយមក ពួកគេមានការយល់ដឹង ហើយបានបញ្ជូនកូនពួកគេទៅសាលារៀន។ នៅទីបញ្ចប់ ពួកគេងាកមកអគុណ និងលើកទឹកចិត្ដពួកយើងឱ្យធ្វើការបន្ដទៀតជាមួយគ្រួសារដទៃ ដែលមិនទាន់នូវតម្លៃនៃការសិក្សា។

"ខ្ញុំបានរៀនពីរបៀបជាអ្នកដឹកនាំ ហើយខ្ញុំមានភាពក្លាហានក្នុងការនិយាយទៅកាន់មនុស្សដែលមានអាយុច្រើនជាងខ្ញុំ។ ខ្ញុំរីករាយជាខ្លាំងក្នុងការធ្វើកិច្ចការទាំងនេះ"។

"យើងបានធ្វើការក្នុងភូមិចំនួនបី និងបំផុសបំផុលឲ្យកុមាររាប់រយនាក់ទៅសាលារៀន"។

ក្នុងនាមជាសិស្សល្អ និងតំណាងសិស្សទាំងអស់ សិរីវឌ្ឍបានចូលរួមដោះស្រាយបញ្ហាមិត្ដភក្ដិរបស់គាត់ ដែលមកពីគ្រួសារក្រីក្របំផុតដែលបម្រុងនឹងបោះបង់ការសិក្សា ដោយមូលហេតុចំណាកស្រុក។ គាត់កំពុងធ្វើការងារជាមួយគ្រូ និងមិត្ដភក្ដិដទៃ ដើម្បីបង្កើតថវិកាសង្គ្រោះសម្រាប់ទិញសម្ភារសិក្សា។

"ឥឡូវនេះ ទោះបីជាឪពុកម្ដាយទៅធ្វើការក្រៅប្រទេស ពួកគេតែងតែផ្ញើរកូនតូចៗរបស់ពួកគេនៅផ្ទះជាមួយជីដូនជីតា ដើម្បីឱ្យកូនៗទាំងនោះអាចទៅសាលារៀន។ នេះពិតជាខុសប្លែកពីមុន ដែលពួកគាត់បាននាំកូនៗរបស់ខ្លួនទៅជាមួយ ដែលធ្វើឱ្យកុមារខកខានពុំបានទៅរៀន"។

# ការចែករំលែកក្តីស្រឡាញ់



អង្គការទស្សនៈពិភពលោកចង់ឲ្យកុមារគ្រប់រូបទទួលបានក្តីស្រលាញ់ និងចិត្តសប្បុរសពីមាតាបិតា និងអ្នកថែទាំរបស់ពួកគេ។ ហេតុដូច្នេះហើយបានជាក្នុងឆ្នាំ២០១២នេះ អង្គការទស្សនៈពិភពលោកបានបង្កើតកម្មវិធីបណ្តុះបណ្តាលព្រលឹងវិញ្ញាណកុមារ ដោយបានចាប់ដៃគូជាមួយអាជ្ញាធរ និងក្រុមជំនុំក្នុងមូលដ្ឋាន ព្រមទាំងគ្រូបង្រៀន និងឪពុកម្តាយទាំងឡាយ។ តាមរយៈកម្មវិធីនេះ មនុស្សធំបានឈប់ប្រើប្រាស់អំពើហិង្សា និងដាក់ទណ្ឌកម្មមិនសមរម្យចំពោះកុមារ។ ជំនួសមកវិញពួកគាត់បានជំរុញទឹកចិត្តឲ្យក្លាយជាអ្នកថែទាំដ៏ល្អ ដែលបង្ហាញនូវក្តីស្រឡាញ់ចំពោះកូនៗរបស់ពួកគាត់។

គ្រូបង្រៀននៅក្នុងក្រុមជំនុំថ្ងៃអាទិត្យ បានអប់រំកុមារមកពីគ្រប់ជំនឿគោរពវប្បធម៌របស់ពួកគេ ហើយមិនអូសទាញពួកគេចូលក្នុងជំនឿណាមួយឡើយ។

មានក្រុមជំនុំកាន់តែច្រើនឡើង បានចូលរួមដោះស្រាយនូវបញ្ហាបន្ទាន់ក្នុងសហគមន៍របស់ពួកគេ ដូចជាការឆ្លើយតបនឹងគ្រោះមហន្តរាយជាដើម។ នេះជាលើកទីមួយហើយ ដែលសមាជិកសហគមន៍ បានមើលឃើញនូវតួនាទីយ៉ាងសំខាន់ របស់ព្រះវិហារនៅក្នុងសហគមន៍របស់ពួកគេ។





# ជាពន្លឺសម្រាប់ពិភពលោក

" ព័ន្ធកិច្ចព្រះជាម្ចាស់នឹងបន្តរីកធំធាត់ក្នុងសហគមន៍របស់ខ្ញុំ។ ខ្ញុំនឹងបន្តបម្រើព្រះជាម្ចាស់ "។

សិរីវឌ្ឍ
១៥





រស់នៅជាកុមារកំព្រាម្នាក់ កុមារី រីម ស្រីលីម មានអាយុ១៥ឆ្នាំ ធ្លាប់ជាកុមារីម្នាក់ដែលមានចរិតឆាប់ខឹង ចូលចិត្តកុហក និងមិនដែលគិតខ្វល់ខ្វាយពីមនុស្សដទៃឡើយ។ ឪពុករបស់នាងបានបោះបង់នាងចោលតាំងពីនាងនៅតូច ដោយទុកឱ្យនាងរស់នៅដោយគ្មានក្តីសង្ឃឹម។ នេះជាមូលហេតុដែលនាំឱ្យនាងរស់នៅដោយគ្មានទំនុកចិត្តលើក្តីស្រលាញ់ពីអ្នកដទៃ។

ព្រះគម្ពីរយ៉ូហាន ជំពូកទី១៣ ៖៣៤-២៥បានថ្លែងថា "ខ្ញុំឲ្យបញ្ញត្តិអ្នករាល់គ្នា គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក។ អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។ បើអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់ពិតជាដឹងថាអ្នករាល់គ្នាពិតជាសិស្សរបស់ខ្ញុំ ពិតប្រាកដមែន"។ ខគម្ពីរនេះពិតជាប៉ះពាល់ដល់ចិត្តស្រីលីម យ៉ាងខ្លាំង ព្រោះតែនាងមិនបានទទួលក្តីស្រឡាញ់ពីឪពុកនាងតាំងតែពីនាងមានអាយុ១៣ឆ្នាំមកម្ល៉េះ។

ការដែលមើលឃើញព្រះជាម្ចាស់ជាឪពុករបស់ខ្លួន បានធ្វើឲ្យស្រីលីមយល់ពីក្តីស្រឡាញ់ពិត ដែលបានបាត់បង់តាំងពីជាយូរមកហើយ។

ស្រីលីម រៀនពីរបៀបអធិស្ឋានទៅកាន់ព្រះជាលើកដំបូង។ ព្រះតែងតែឆ្លើយតបនូវរាល់សំនូមពររបស់នាង។ "ក្តីស្រឡាញ់ក្នុងលោកមិនដែលទៀងទាត់ឡើយ ប៉ុន្តែក្តីស្រឡាញ់ពីព្រះគឺនៅអស់កល្បជានិច្ច។ ទ្រង់តែងតែគង់ជាមួយខ្ញុំ ហើយទ្រង់ជាបិតារបស់ខ្ញុំ។

បន្ទាប់ពីបានស្គាល់ព្រះ ស្រីលីមចេះអនុគ្រោះដល់អ្នកដទៃ ដែលខុសប្លែកពីមុន ដែលនាងចង់តែវាយតតាំងនឹងអ្នកដទៃ ដែលបានធ្វើខុសឆ្គងលើនាង។ សព្វថ្ងៃនេះ ស្រីលីមចូលចិត្តពន្យល់នូវក្តីស្រឡាញ់នៃព្រះ ទៅដល់មិត្តភក្តិ និងអ្នកជិតខាងរបស់នាង។



# ការការពារក្នុងកំឡុងពេលមានមហន្តរាយ កាត់បន្ថយហានិភ័យនាពេលអនាគត




ទឹកជំនន់ឆ្នាំ២០១១ បានបង្កផលអាក្រក់ដល់ប្រជាជនចំនួន ១.២នាក់ក្នុង១៧ខេត្តចំណោម២៤ខេត្តក្រុងនៅកម្ពុជា។ ស្រូវជាង៩០.០០០ហិកតា និងដំណាំគ្រាប់ពូជ៦.៤០០ហិកតា ត្រូវបានបំផ្លាញ។

កម្មវិធីអភិវឌ្ឍន៍តំបន់អង្គការទស្សនៈពិភពលោកចំនួន៧ ក្នុងខេត្តកំពង់ធំ និងកណ្តាលបានផ្តោតលើការផ្តល់សន្តិសុខស្បៀង អនាម័យនិងទឹកស្អាត ទីជម្រក ផ្តល់ការអប់រំសុខភាព កុមារ និងការដោះស្រាយបញ្ហាផ្សេងៗទៀត។

ដើម្បីកាត់បន្ថយហានិភ័យ និងផលប៉ះពាល់អវិជ្ជមានដល់ជីវិតកុមារក្នុងកំឡុងគ្រោះមហន្តរាយ គម្រោងកាត់បន្ថយគ្រោះភ័យគ្រោះមហន្តរាយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរបស់អង្គការទស្សនៈពិភពលោក បានធ្វើការជាមួយ ឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារពីការត្រៀមរៀបចំខ្លួនសម្រាប់គ្រោះមហន្តរាយដែលអាចកើតមានឡើង។ តាមរយៈការសាងសមត្ថភាពសហគមន៍បានរៀនពីវិធីការពារកុមារពីការរំលោភបំពាន និងការកេងប្រវ័ញ្ច ដូចជាវិធីទទួលយកសេវាសុខភាពសំខាន់ៗ ទទួលការអប់រំជាមូលដ្ឋាន និងវិធីបង្កើតបរិដ្ឋានស្អាតបន្ទាប់ពីគ្រោះមហន្តរាយបានបំផ្លិចបំផ្លាញ។





**ប្រជាជនចំនួន**

**១៧.០០០នាក់**

ក្នុងខេត្តកំពង់ធំ និងខេត្តកណ្តាលបានទទួលផលប្រយោជន៍ពីគម្រោងស្តារឡើងវិញពីគ្រោះមហន្តរាយ ក្នុងឆ្នាំ ២០១២



**ស្ត្រីចំនួន**

**៨.៤០០នាក់** និង

**កុមារចំនួន**

**៦.៥០០នាក់**

បានទទួលផលពីគម្រោងនេះ

# កិច្ចការងារមនុស្សធម៌ និងជំនួយសង្គ្រោះបន្ទាន់



" ខ្ញុំយកទឹកស្អាតនេះ ដើម្បីទទួលទាន នៅសាលារៀនជារៀងរាល់ថ្ងៃ។ ខ្ញុំ ចូលចិត្តទទួលទានទឹកនេះ ព្រោះវាល្អ និង មានសុវត្ថិភាពសម្រាប់សុខភាពរបស់ខ្ញុំ "។

សុខហេង

១២

## ដំណើរការដើម្បីទឹកស្អាតការពារដល់ស្ត្រី និងកុមារ កំឡុងពេលគ្រោះមហន្តរាយ

បន្ទាប់ពីគ្រោះមហន្តរាយទឹកជំនន់ឆ្នាំ ២០១១ ទឹក និងស្បៀង ស្ថិតក្នុងចំណោមតំរូវការបន្ទាន់បំផុត សម្រាប់ប្រជាជនក្នុងភូមិព្រៃកតាអុង ខេត្តកណ្តាល។

ផុន ស៊ីណា អាយុ ៣៣ឆ្នាំ បាននិយាយថា៖ "យើងពិបាករកទឹកស្អាតបរិភោគ បើទោះបីជាមានប្រភពទឹកនៅជុំវិញផ្ទះរបស់យើងក៏ដោយ។ យើងគ្មានអុសដុតសម្រាប់ដាំទឹកទេ"។

អង្គការទស្សនៈពិភពលោកបានស្តារអណ្តូងទឹក និងសង់បង្គន់អនាម័យថ្មីៗនៅតាមសាលាក្នុងសហគមន៍ដែលរងផលប៉ះពាល់ពីគ្រោះទឹកជំនន់ក្នុងខេត្តកណ្តាល។ បុគ្គលិកអង្គការទស្សនៈពិភពលោកបានផ្តល់ការបណ្តុះបណ្តាលស្តីពីអនាម័យ និងទឹកស្អាតទៅដល់ប្រជាសហគមន៍ និងសិស្សានុសិស្ស។ ស្រះទឹកសហគមន៍ចំនួនពីរត្រូវបានសម្អាត និងជួសជុលសម្រាប់ការប្រើប្រាស់តាមផ្ទះ និងស្រោចស្រពដំណាំកសិកម្ម។

លោកសូ សូជាតិ ប្រធានគម្រោងស្តារឡើងវិញក្រោយគ្រោះទឹកជំនន់របស់អង្គការទស្សនៈពិភពលោក មានប្រសាសន៍ថា "ដើម្បីការពារសុខភាពប្រជាជន យើងត្រូវគិតពីការបរិភោគទឹកស្អាត អនាម័យ និងសន្តិសុខស្បៀង ដើម្បីឱ្យពួកគេរួចផុតពីផលប៉ះពាល់ដោយសារគ្រោះទឹកជំនន់ធ្ងន់ធ្ងរ"។

គ្រួសាររបស់ពន្លក សុខហេង ស្ថិតក្នុងចំណោមគ្រួសាររងគ្រោះពីផលប៉ះពាល់នៃទឹកជំនន់ក្នុងភូមិព្រៃកតាអុង។ គ្រួសាររបស់គាត់មានទឹកស្អាតសម្រាប់ទទួលទាន ក្រោយពីទទួលបានថ្នាំបន្សុទ្ធទឹកឱ្យស្អាត ដែលជួយសន្សំគាត់ ទាំងពេលវេលា ទាំងប្រាក់កាស។

ម្តាយរបស់ហេងបានប្រាប់ថា "ពីមុន ខ្ញុំចំណាយពេលច្រើនដើម្បីដាំទឹកជារៀងរាល់ថ្ងៃ។ ប៉ុន្តែ ឥឡូវនេះ ខ្ញុំមិនបាច់ធ្វើដូច្នេះទៀតទេ"។

គ្រួសារសរុបចំនួន ១.១១៤គ្រួសារ រស់នៅក្នុងស្រុកល្វាឯមបានទទួលថ្នាំបន្សុទ្ធទឹក ពាងមួយ ធុងទឹក និងគ្រាប់ពូជបន្លែ។ ពួកគេត្រូវបានបង្រៀនពីរបៀបដាំដំណាំ និងលក់កសិផលទាំងនោះនៅតាមទីផ្សារដែលនៅជិតៗនោះ ដើម្បីបង្កើនប្រាក់ចំណូល។

គម្រោងស្តារឡើងវិញក្រោយគ្រោះទឹកជំនន់របស់អង្គការទស្សនៈ-ពិភពលោក បានផ្តល់ប្រយោជន៍ដល់ប្រជាជនចំនួន ៦.០០០គ្រួសារ ស្មើនឹងប្រជាជនប្រមាណ ២៧.០០០នាក់ ដែល១២.៨៤២នាក់ជាកុមារក្នុងខេត្តកំពង់ធំ និងខេត្តកណ្តាល។ ការអប់រំ និងការយល់ដឹងស្តីអំពីការត្រៀមខ្លួន និងការកាត់បន្ថយគ្រោះហមហន្តរាយត្រូវបានពង្រឹងនៅតាមតំបន់ងាយរងផលប៉ះពាល់ពីគ្រោះទឹកជំនន់។



# វិនិយោគដើម្បីជីវិតប្រសើរឡើងសម្រាប់កុមារ

ក្នុងឆ្នាំ២០១២ វីសិនហ្វាន់ខេមបូឌាបានឈានទៅដល់ជំហានដ៏គួរឲ្យកត់សម្គាល់ក្នុងការបម្រើសេវាកម្មហិរញ្ញវត្ថុរបស់ខ្លួនទៅដល់សហគមន៍ដែលមានអតិថិជនរហូតដល់ជាង ១៥០.០០០នាក់។ ជាមួយការពង្រីកសាខាក្នុងខេត្តចំនួន២០ មានកុមារជាងកន្លះលាននាក់ បាននិងកំពុងទទួលបានផលប៉ះពាល់ជាវិជ្ជមានពីការងាររបស់វីសិនហ្វាន់។



អតិថិជនចំនួន

**១៥០.០០០នាក់**

ខេត្តចំនួន

**២០**



ប៉ះពាល់ដល់

កុមារចំនួនច្រើនជាង

**កន្លះលាននាក់**

ច្រើនជាង៨៥% នៃអតិថិជនដែលទទួលបានសេវាហិរញ្ញវត្ថុពីវីសិនហ្វាន់ គឺជាប្រជាជនរស់នៅតំបន់ជនបទ ដែល ៣០%នៃពួកគេអាចរកចំណូលបានជាមធ្យមតិចជាង ១,២៥ ដុល្លារអាមេរិក (៥០០០ រៀល)ក្នុងមួយថ្ងៃ។ ការពង្រីកសេវាកម្មហិរញ្ញវត្ថុដល់ប្រជាជនតាមជនបទ អនុញ្ញាតឲ្យពួកគេចាប់ផ្តើម និងពង្រីកមុខរបររបស់ពួកគេដើម្បីមានជីវភាពរស់នៅកាន់តែប្រសើរជាងមុន។



អតិថិជនចំនួន

**៨៥%**

ជាប្រជាជនក្រីក្រ
រស់នៅតំបន់ជនបទ

តាមការស្ទង់មតិនៅក្នុងស្រុកផ្សេងៗជាច្រើនក្នុងខេត្តតាកែវ និងបាត់ដំបងបានបង្ហាញថា៖



ប្រជាជនបានទទួលអាហារូបត្ថម្ភបន្ថែមដូចជា ត្រី និងសាច់។ ប្រជាជនដែលទទួលទានត្រី ៤ដងក្នុង១សប្តាហ៍ កើនឡើងពី ០% ទៅ ៤%។ ដូចគ្នានេះដែរ សម្រាប់ប្រជាជនដែលទទួលទានសាច់ កើនឡើងពី ៤% ទៅ ២៣%



ប្រជាជនចំនួន ១១.០០០ គ្រួសារ បានប្រើប្រាស់ប្រាក់កម្ចីរបស់វីសិនហ្វាន់ដើម្បីទិញធុងចម្រោះទឹកស្អាត ហើយគ្រួសារចំនួន ១.៣៥០ ទៀតបានប្រើប្រាស់កម្ចី ដើម្បីកសាងបង្គន់អនាម័យ។ កម្ចីទាំងនេះ បានផ្តល់នូវអត្ថប្រយោជន៍ជាទឹកស្អាត និងអនាម័យរស់នៅល្អ សម្រាប់កុមារជិត ៥០.០០០ នាក់



កុមារចំនួន៤៦នាក់ ដែលជាកូនអតិថិជន ឆ្នើមរបស់វីសិនហ្វាន់ បានទទួលផលប្រយោជន៍យូរអង្វែង ពីកម្មវិធីអាហារូបករណ៍របស់ វីសិនហ្វាន់រហូតដល់ចប់ថ្នាក់ទី១២



អាជីវកម្មបែបគ្រួសារដែលមានបុគ្គលិកបម្រើការអាចនឹងត្រូវបានពង្រីកម៉ោងការងារអាជីវកម្មបន្ថែមដើម្បីបង្កើនសង្វាក់ផលិតកម្មរបស់ពួកគេ



ប្រជាជនបានបង្កើនការយល់ដឹងពីការទទួលទានទឹកស្អាត




# សារិនទទួលក្តីសង្ឃឹមថ្មី

កាលពី១០ឆ្នាំមុន ការគិតពីក្តីសង្ឃឹម និងអនាគតហាក់បីដូចជាស្រមើលស្រមៃសម្រាប់ រិន សារ៉េន។ ប្តីរបស់គាត់ឈ្មោះ ហូ ម៉ារា ធ្វើការជាកម្មករសំណង់ ហើយគាត់ត្រូវប្រកបការងារឆ្ងាយពីផ្ទះទៀត។

នៅឆ្នាំ២០០២ សារិន បានទទួលប្រាក់កម្ចីជាលើកដំបូងចំនួន១៣ដុល្លារសហរដ្ឋអាមេរិក ពីវីសិនហ្វាន់ដើម្បីទិញឧបករណ៍នេសាទ។ ឧបករណ៍នេសាទនេះហើយ ដែលបាននាំឱ្យគាត់ចាប់ផ្តើមមានជីវភាពប្រសើរ មុនពេលគាត់ទទួលយកប្រាក់កម្ចីជាលើកទីពីរចំនួន១៥០ដុល្លារអាមេរិក សម្រាប់ទិញម៉ូតូ និងកូនជ្រូកដើម្បីលក់នៅភូមិផ្សេងទៀត។

នៅឆ្នាំ២០០៨ ដោយមានកូនតូចៗចំនួន៤នាក់នៅក្នុងបន្ទុក ម៉ារា និង សារិន  បានខ្ចីប្រាក់បន្ថែមទៀតចំនួន២០០ ដុល្លារសហរដ្ឋអាមេរិកដើម្បីទិញឧបករណ៍សាកអាគុយ។ ឧបករណ៍សាកអាគុយ បានក្លាយជាមុខរបរមួយដ៏ពេញនិយម ដោយសារតែមានគ្រួសារជាច្រើន នៅជនបទនិយមប្រើអាគុយរថយន្តសម្រាប់ជាថាមពលអគ្គីសនីសម្រាប់បំភ្លឺផ្ទះរបស់ពួកគេ។សព្វថ្ងៃនេះ គាត់អាចរកចំណូលរហូតដល់២០ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយថ្ងៃ ហើយនៅសល់ចំនួន ៧ដុល្លារសហរដ្ឋអាមេរិក មកផ្ទះជារៀងរាល់ថ្ងៃក្រោយពីទូទាត់ចំណាយទាំងអស់។

ចំណែកសារិន ដែលយកប្រាក់កម្ចីមកទិញជ្រូក ចំណីជ្រូក ថ្នាំបង្ការ ដើម្បីចិញ្ចឹមវា និងលក់ជារៀងរាល់៤ខែម្តង ដើម្បីបង្វិលលុយសងវីសិនហ្វាន់ បាននិយាយថា៖ "យើងធ្វើការសម្រេចចិត្តដាក់ទុនបង្កើនមុខរបរសាកអាគុយ ដើម្បីយកចំណូលនោះមកទិញកូនជ្រូក ដើម្បីចិញ្ចឹមបន្ថែម" ស្របពេលគ្នានោះដែរ ពួកគេអាចធ្វើស្រែបានពីរដង ក្នុងមួយឆ្នាំបន្ទាប់ពីពួកគេខ្ចីប្រាក់ ២៥០ដុល្លារសហរដ្ឋអាមេរិកបន្ថែមទៀត សម្រាប់ទិញម៉ាស៊ីនបូមទឹកដើម្បីបង្កើនទិន្នផល។

សារ៉េនបានប្រាប់ឱ្យដឹងថា "សុខភាពកូនៗរបស់ពួកយើងមានលក្ខណៈប្រសើរឡើង។ "ជារឿយៗ ពួកគេធ្លាប់តែមានជំងឺដូចជាគ្រុនក្តៅ និងរាករូស ដែលធ្វើឱ្យពួកយើងមានការព្រួយបារម្ភជាពន់ពេក។ ឥឡូវនេះ យើងមានលទ្ធភាពទិញឱសថ រៀងរាល់ពេលដែលយើងត្រូវការ"។

ម៉ារានិយាយថា៖ "ខ្ញុំចង់ឱ្យកូនរបស់ខ្ញុំក្លាយជាវេជ្ជបណ្ឌិត និងមានការងារល្អ" បើមើលតាមកម្រិតចំណូលសព្វថ្ងៃ ម៉ារាបានបន្ថែមថា ពួកគេមានថវិកាគ្រប់គ្រាន់ក្នុងការឱ្យកូនៗបន្តការសិក្សារហូតដល់ថ្នាក់វិទ្យាល័យ។



## ចំណាយសម្រាប់ឆ្នាំ ២០១២

ចំណាយសរុបចំនួន **$២២** លានដុល្លារអាមេរិក

ចំណាយសម្រាប់ឆ្នាំ២០១២ លើសឆ្នាំ២០១១ ចំនួន **១៣%** ឬ **$២.៥** លានដុល្លារអាមេរិក




## ចំណាយសាច់ប្រាក់តាមប្រទេសផ្តល់ជំនួយ

| | | |
|---|---|---|
| អូស្ត្រាលី | $ ៤.៤០២.៤៩៩ | ២១% |
| កម្ពុជា | $ ២៣៩.៩៥៥ | ១% |
| កាណាដា | $ ២.៧៥២.៧៣៣ | ១៣% |
| អាឡឺម៉ង់ | $ ១.១៤៦.៩១៨ | ៥% |
| ហុងកុង | $ ២.៤៣៩.៩៨៦ | ១១% |
| ជប៉ុន | $ ៧៨២.៥០៨ | ៤% |
| កូរ៉េ | $ ៦៩៥.២៣៩ | ៣% |
| ភូមា | $ ២៥៣.៧៤៣ | ១% |
| ហូឡង់ | $ ២៤១.៨៧៦ | ១% |
| ណូវែលសេឡង់ | $ ១.១៤៥.៨៣៥ | ៧% |
| សិង្ហបុរី | $ ៧៦៦.៥១០ | ៤% |
| ស្វីស | $ ១៩៣.២៣៦ | ១% |
| តៃវ៉ាន់ | $ ១៩៧.៨៨២ | ១% |
| ចក្រភពអង់គ្លេស | $ ២.១០៤.៨០២ | ១០% |
| សហរដ្ឋអាមេរិក | $ ៣.៦៦៤.៣៥០ | ១៧% |
| **សរុប** | **$ ២១.២៩៨.០៧២** | **១០០%** |

## ចំណាយសាច់ប្រាក់តាមប្រភេទជំនួយ

**កម្មវិធីទំនុកបម្រុង**

$ ១៤.៩៦៥.៤៩៩ = ៧០%

**ឯកជន មិនមែនកម្មវិធីទំនុកបម្រុង**

$ ៤.៤៨៩.៧៦៤ = ២១%

**រដ្ឋាភិបាល**

$ ១.៨៤១.៨០៩ = ៩%




## ចំណាយសាច់ប្រាក់តាមប្រភេទចំណាយ

**ចំណាយតាមគម្រោងផ្ទាល់**

$ ១៩.២៣៦.០២៧ = ៩១%

**ចំណាយតាមគម្រោងមិនផ្ទាល់**

$ ២.០៦២.០៣៥ = ៩%




## ចំណាយលើគម្រោងផ្ទាល់តាមផ្នែក

| | | |
|---|---|---|
| ផ្នែកកុមារស្ថិតក្នុងវិបត្តិ និងការការពារ | $ ២.៤២០.៥២៩ | ១១% |
| ផ្នែកសុខភាព អាហារូបត្ថម្ភ អេដស៍ និងអនាម័យទឹកស្អាត | $ ៤.៦០៥.៤៨៤ | ២២% |
| ផ្នែកសង្គមស៊ីវិល និងការតស៊ូមតិ | $ ២.៧៨២.១៤៩ | ១៣% |
| ផ្នែកគ្រប់គ្រងកម្មវិធីទំនុកបំរុង | $ ២.៣៩១.៤១៨ | ១១% |
| ផ្នែកសន្តិសុខស្បៀង និងកសិកម្ម | $ ១.២៤៩.៩៣៣ | ៦% |
| ផ្នែកអប់រំ | $ ១.២៥៩.៦៤៣ | ៦% |
| ផ្នែកកាត់បន្ថយគ្រោះមហន្តរាយ និងឆ្លើយតបសង្គ្រោះបន្ទាន់ | $ ៦២៣.៤៧១ | ៣% |
| ផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន | $ ៤៥៦.៩៧៤ | ២% |
| ផ្នែកព័ន្ធកិច្ច គ្រីស្តបរិស័ទ | $ ២៦១.៦៤៣ | ១% |
| ផ្នែកតាមដាន និងវាយតម្លៃ និងវាយតម្លៃចងក្រង | $ ៧៣២.០១៤ | ៣% |
| ផ្នែកគ្រប់គ្រងកម្មវិធី និងគម្រោង | $ ៤.៥១៤.៨០៤ | ២១% |
| **សរុប** | **$ ២១.២៩៨.០៧២** | **១០០%** |

## អាហារ និងអំណោយផ្សេងៗ

បន្ថែមលើសាច់ប្រាក់ យើងបានទទួល និងចែកចាយអាហារ និងអំណោយផ្សេងៗ ដូចខាងក្រោម៖

- អាហារបានមកពីអង្គការស្បៀងអាហារពិភពលោកដែលមានទឹកប្រាក់ចំនួន ៧៤២.៣៧៧ដុល្លារសហរដ្ឋអាមេរិក
- សម្ភារមិនមែនជាអាហារមានទឹកប្រាក់ចំនួន១៩.៩៤២ដុល្លារសហរដ្ឋអាមេរិក រួមមានចង្កៀងប្រើថាមពលព្រះអាទិត្យ ចំនួន ៧០៩។

សាច់ប្រាក់ទាំងអស់ខាងលើគិតជាដុល្លារអាមេរិក

**រចនាក្រាហ្វិក និងកាត់ទំព័រដោយ**
រចនាឌីហ្សាញ www.rachnadesign.com skaishann@rachnadesign.com

**អត្ថបទ និងរូបថតដោយ**
ក្រុមទំនាក់ទំនងព័ត៌មាន និងសារព័ត៌មាន, ភ្នំពេញ
ក្រុមសម្របសម្រួលទីផ្សារ និងរកមូលនិធិរបស់វីសិនហ្វាន់កម្ពុជា

**បោះពុម្ពផ្សាយនៅកម្ពុជាក្នុងឆ្នាំ ២០១៣**
ផ្នែកនៃព័ត៌មាននេះអាចនឹងបោះពុម្ពផ្សាយបន្ត ប្រសិនបើមានការអនុញ្ញាត។ របាយការណ៍នេះអាចរកបានពីអង្គការទស្សនៈពិភពលោកកម្ពុជា។

World Vision®

## អង្គការទស្សនៈពិភពលោកកម្ពុជា


អាគារលេខ២០ ផ្លូវលេខ៧១
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
ប្រអប់សំបុត្រ លេខ៤៧៩
ភ្នំពេញ–កម្ពុជា
ទូរស័ព្ទ: +៨៥៥–២៣–២១៦ ០៥២
ទូរសារ: +៨៥៥–២៣–២១៦ ២២០

អ៊ីម៉ែល: cambodia@wvi.org
www.worldvision.org.kh

www.facebook.com/WVCambodia

@WVCambodia


